# កូនសោដ៏ពិសិដ្ឋនៃបព្វជិតភាពអើរ៉ុន

បងប្រុស លែរី អិម ហ្គិបសិន
ទីប្រឹក្សាទីមួយនៃគណៈប្រធានយុវជនទូទៅ

*ព្រះអម្ចាស់ចង់ឲ្យអ្នកកាន់បព្វជិតភាពអើរ៉ុនគ្រប់គ្នាអញ្ជើញមនុស្សទាំងអស់មករកព្រះគ្រីស្ទ ---ដោយចាប់ផ្ដើមពីគ្រួសារគេផ្ទាល់ ។*

កាលពីកូនប្រុសខ្ញុំម្នាក់មានអាយុ 12 ឆ្នាំ គាត់សម្រេចចិត្តចិញ្ចឹមទន្សាយ ។ យើងបានសង់ទ្រុង ហើយបានទន្សាយបីក្បាលពីអ្នកជិតខាងម្នាក់គឺឈ្មោលមួយ មេពីរ ។ ខ្ញុំមិនដឹងថាត្រូវធ្វើយ៉ាងម៉េចនោះឡើយ ។ ក្នុងពេលមួយដ៏ខ្លី ផ្ទះរបស់យើងគឺពោរពេញទៅដោយសត្វទន្សាយ ។ ឥឡូវដោយកូនប្រុសខ្ញុំធំហើយ ខ្ញុំត្រូវតែសារភាពពីការភ្ញាក់ផ្អើលរបស់ខ្ញុំចំពោះរបៀបនៃការគ្រប់គ្រងវា --- គឺម្ដងម្កាលមានឆ្កែអ្នកជិតខាងចូលមកក្នុងផ្ទះ ហើយបានស៊ីពួកវាមួយចំនួន ។

តែដួងចិត្តខ្ញុំមានក្ដីរំភើប ពេលឃើញកូនប្រុសខ្ញុំ និងប្អូនប្រុសគាត់ពីរនាក់ទៀតថែរក្សា ហើយការពារដល់ទន្សាយទាំងនោះ ។ ហើយឥឡូវនេះ ក្នុងនាមជាស្វាមី និងជាឪពុក ពួកគេគឺជាអ្នកកាន់បព្វជិតភាពដ៏សក្ដិសម និងជាអ្នកដែលស្រឡាញ់ ពង្រឹង និងការពារដល់គ្រួសារខ្លួន ។

ខ្ញុំមានចិត្តរំភើប ពេលសង្កេតឃើញអ្នករាល់គ្នាដែលជាយុវជននៃបព្វជិតភាពអើរ៉ុនកំពុងតែមើលថែ ជួយ និងពង្រឹងដល់អ្នកនៅជុំវិញខ្លួន រួមមានគ្រួសារអ្នក និងសមាជិកកូរ៉ុមរបស់អ្នក ។ ខ្ញុំស្រឡាញ់អ្នកខ្លាំងណាស់ ។

ថ្មីៗនេះខ្ញុំបានសម្លឹងមើលពេលដែលយុវជនអាយុ 13 ឆ្នាំម្នាក់ត្រូវបានញែកចេញជាប្រធានកូរ៉ុមឌីកុន ។ ក្រោយមក ប៊ីស្សពបានចាប់ដៃគាត់ ហើយប្រកាសគាត់ជា « ប្រធាន » ដោយពន្យល់ទៅសមាជិកកូរ៉ុមថា គាត់ប្រកាសយុវជននេះជាប្រធានដើម្បីគូសបញ្ជាក់ពីភាពពិសិដ្ឋនៃការហៅរបស់គាត់ ។ ប្រធានកូរ៉ុមឌីកុនគឺជាមនុស្សម្នាក់ក្នុងចំណោមមនុស្សបួននាក់នៅក្នុងវួដដែលកាន់កូនសោនៃគណៈប្រធាន ។ គាត់ និងទីប្រឹក្សារបស់គាត់នឹងដឹកនាំកូរ៉ុមនេះនៅក្រោមការបំផុសគំនិតពីព្រះអម្ចាស់ជាមួយនឹងកូនសោទាំងនោះ » ។ ប៊ីស្សពរូបនេះបានយល់ពីអំណាចនៃ
គណៈប្រធានដែលដឹកនាំដោយប្រធានម្នាក់ដែលកាន់ និងអនុវត្តនូវកូនសោដ៏ពិសិដ្ឋនានា (សូមមើល គ. និង ស. 124:142-143 ) ។ ក្រោយមកខ្ញុំបានសួរទៅយុវជននេះថាតើគាត់បានតាំងចិត្តរួចរាល់ហើយឬនៅ ដើម្បីដឹកនាំកូរ៉ុមដ៏អស្ចារ្យនេះ ។ គាត់ឆ្លើយថា « ខ្ញុំភ័យណាស់ ។ ខ្ញុំមិនដឹងថាប្រធានកូរ៉ុមឌីកុនម្នាក់ត្រូវធ្វើអ្វីខ្លះទេ ។ តើលោកអាចប្រាប់ខ្ញុំបានទេ ? »

ខ្ញុំបានប្រាប់គាត់ថា គាត់មានគណៈប៊ីស្សព និងអ្នកណែនាំដ៏ល្អ នៅចាំជួយគាត់ឲ្យក្លាយជាអ្នកដឹកនាំបព្វជិតភាពម្នាក់ដ៏មានជោគជ័យ ។ ខ្ញុំបានដឹងថា ពួកគាត់នឹងគោរពដល់កូនសោដ៏ពិសិដ្ឋនៃគណៈប្រធានដែលគាត់កាន់ ។

រួចខ្ញុំបានចោទសួរថា ៖ « តើប្អូនគិតថាព្រះអម្ចាស់បានហៅប្អូនក្នុងការហៅដ៏សំខាន់នេះដោយគ្មានផ្ដល់ឲ្យប្អូននូវការដឹកនាំមែនទេ ? »

គាត់បានគិត រួចក៏ឆ្លើយថា « តើខ្ញុំអាចរកវានៅឯណាបាន ? »

បន្ទាប់ពីការពិភាក្សាខ្លះៗមក គាត់ដឹងថាគាត់អាចស្វែងរកការដឹកនាំពីព្រះគម្ពីរ ពាក្យពេចន៍នៃពួកព្យាការីនៅរស់ និងចម្លើយចំពោះការអធិស្ឋាន ។ យើងបានកំណត់រកខគម្ពីរមួយដែលជាកន្លែងចាប់ផ្ដើមសម្រាប់ការស្វែងរករបស់គាត់ ដើម្បីរៀនពីទំនួលខុសត្រូវក្នុងការហៅថ្មីរបស់គាត់ ។

យើងបានបើកទៅកណ្ឌទី 107 ក្នុងគោលលទ្ធិ និងសេចក្ដីសញ្ញា ខទី 85 ។ ខនោះបានចែងថា ប្រធានកូរ៉ុមឌីកុនម្នាក់គឺត្រូវអង្គុយជាមួយនឹងសមាជិកកូរ៉ុមគាត់ក្នុងក្រុមប្រឹក្សា ហើយបង្រៀនពួកគេពីភារកិច្ចរបស់គេ ។ យើងបានកត់សំគាល់ឃើញថា កូរ៉ុមគាត់គឺពុំមែនជាថ្នាក់មួយឡើយ ប៉ុន្តែជាក្រុមប្រឹក្សាយុវជនមួយ ហើយពួកគេពង្រឹង និងលើកស្ទួយគ្នា ក្រោមការដឹកនាំរបស់ប្រធាន ។ ខ្ញុំបានសម្ដែងការជឿជាក់ថា គាត់នឹងក្លាយជាប្រធានម្នាក់ដ៏ឆ្នើមដែលពឹងផ្អែកទៅលើការបំផុសគំនិតពីព្រះអម្ចាស់ ហើយលើកតម្កើងដល់ការហៅដ៏ពិសិដ្ឋរបស់ខ្លួន ពេលគាត់បង្រៀនសមាជិកគាត់ពីភារកិច្ចគេ ។

រួចខ្ញុំបានសួរថា « ដោយដឹងថាប្អូនត្រូវបង្រៀនពួកឌីកុនពីភារកិច្ចរបស់គេ តើប្អូនដឹងថាភារកិច្ចទាំងនោះមានអ្វីខ្លះទេ ? »

ជាថ្មីម្តងទៀត យើងបានបើកព្រះគម្ពីរ ហើយក៏រកឃើញថា ៖

1. ឌីកុនម្នាក់ត្រូវបានតាំងឲ្យមើលលើសាសនាចក្រនិងធ្វើជាអ្នកតំណាងព្រះអម្ចាស់ដល់សាសនាចក្រ (សូមមើល គ. និង ស. 81:111 ) ។

ដោយសារគ្រួសារគឺជាអង្គភាពដ៏សំខាន់ក្នុងសាសនាចក្រ នោះមជ្ឈដ្ឋានដ៏សំខាន់បំផុតដែលអ្នកកាន់បព្វជិតភាពអើរ៉ុនម្នាក់អាចបំពេញភារកិច្ចនេះនៅគឺនៅក្នុងផ្ទះរបស់គេផ្ទាល់ ។ គាត់ផ្តល់ជំនួយខាងបព្វជិតភាពដល់ឪពុកម្តាយគាត់ ពេលពួកគាត់ដឹកនាំគ្រួសារ ។ គាត់ក៏មើលថែដល់ប្អូនប្រុសស្រីខ្លួន យុវជននៅក្នុងកូរ៉ុមរបស់គាត់និងសមាជិកវួដផ្សេងទៀតផងដែរ ។

2. ឌីកុនម្នាក់ជួយគ្រូនៅរាល់ភារកិច្ចរបស់គាត់ក្នុងសាសនាចក្របើសិនជាត្រូវការ (សូមមើល គ. និង ស. 20:57 ) ។

យើងបានកំណត់ថា បើឌីកុនម្នាក់ត្រូវជួយដល់ភារកិច្ចរបស់គ្រូ នោះគាត់ត្រូវដឹងពីភារកិច្ចរបស់គេ ។ ក្នុងព្រះគម្ពីរ យើងបានរកឃើញភារកិច្ចមួយចំនួនសម្រាប់តំណែងរបស់គ្រូ ។ (សូមមើល គ. និង ស. 20:53–59, 84:111 ) ។ វាគឺជាបទពិសោធន៍មួយដ៏អស្ចារ្យសម្រាប់យុវជនគ្រប់រូប --- ឪពុក អ្នកណែនាំពួកគេ និងអ្នកដទៃទៀត --- ដើម្បីធ្វើនូវរឿងដូចគ្នាដែលយុវជននេះបានធ្វើគឺ ៖ បើកព្រះគម្ពីរហើយរកដោយខ្លួនឯងថាតើភារកិច្ចយើងមានអ្វីខ្លះ ។ ខ្ញុំគិតថាយើងទាំងអស់នឹងភ្ញាក់ផ្អើល ---ហើយបានបំផុសគំនិត ---ដោយអ្វីដែលយើងរកឃើញ ។ សៀវភៅភារកិច្ចចំពោះព្រះមាននូវសេចក្តីសង្ខេបដ៏មានខ្លឹមសារអំពីភារកិច្ចនៃបព្វជិតភាពអើរ៉ុន ហើយជាធនធានដ៏ល្អបំផុតមួយ សម្រាប់ការអភិវឌ្ឍន៍ខាងវិញ្ញាណ ។ ខ្ញុំសូមជំរុញអ្នកប្រើវាឲ្យបានញឹកញាប់ ។

3. ឌីកុន និងគ្រូក៏ត្រូវ « ព្រមាន ពន្យល់ ទូន្មាន និងបង្រៀន ហើយអញ្ជើញមនុស្សទាំងអស់ឲ្យមករកព្រះគ្រីស្ទ »ដែរ ( គ. និង ស. 20:59 សូមមើល 20:42, 46, 68 សម្រាប់សង្ឃ ) ។

មានយុវជនជាច្រើនគិតថា បទពិសោធន៍ផ្សព្វផ្សាយសាសនារបស់ខ្លួនចាប់ផ្តើមពេលពួកគេអាយុ 19 ឆ្នាំ ហើយចូលទៅមជ្ឈមណ្ឌលហ្វឹកហ្វឺនពួក អ្នកផ្សព្វផ្សាយសាសនា ។ យើងរៀនពីព្រះគម្ពីរថា វាចាប់ផ្តើមពីមុននោះទៅទៀត ។ ព្រះអម្ចាស់ចង់ឲ្យអ្នកកាន់បព្វជិតភាពអើរ៉ុនគ្រប់គ្នាអញ្ជើញមនុស្សទាំងអស់មករកព្រះគ្រីស្ទ ---ដោយចាប់ផ្តើមពីគ្រួសារគេផ្ទាល់ ។

បន្ទាប់មកទៀត ដើម្បីជួយឲ្យប្រធានវ័យក្មេងនេះយល់ថា មានតែគាត់ម្នាក់ប៉ុណ្ណោះដែលមានតំណែងជាអធិបតីក្នុងកូរ៉ុម នោះខ្ញុំបានណែនាំគាត់ឲ្យអានភារកិច្ចដំបូងនៅក្នុងគោលលទ្ធិនិងសេចក្តីសញ្ញា 107:85 ចំនួនបីដង ។ គាត់អានថា « ត្រួតត្រាលើពួកឌីកុន12នាក់ » ។ ខ្ញុំបានសួរថា « តើព្រះអម្ចាស់បានប្រាប់អ្វីខ្លះដល់ប្អូនអំពីភារកិច្ចរបស់ប្អូនជាប្រធាន ? »

គាត់និយាយថា « មានរឿងមួយចំនួនបានផុសឡើងក្នុងគំនិតរបស់ខ្ញុំ ពេលយើងកំពុងពិភាក្សាគ្នា ។ ខ្ញុំគិតថាព្រះវរបិតាសួគ៌ចង់ឲ្យខ្ញុំធ្វើជាប្រធានលើពួកឌីកុន12នាក់ ។ មានតែយើងប្រាំនាក់ប៉ុណ្ណោះដែលមកទៀងទាត់ និងម្នាក់ទៀតមកម្តងម្កាល ។ ចុះតើយើងត្រូវធ្វើម៉េចដើម្បីបាន12នាក់ទៅ ?»

ឥឡូវ ខ្ញុំពុំធ្លាប់បកស្រាយខគម្ពីរនេះតាមរបៀបដែលគាត់បានធ្វើឡើយ តែពេលនោះគាត់បានកាន់កូនសោដ៏ពិសិដ្ឋដែលខ្ញុំគ្មាន ។ ខ្ញុំត្រូវបានបង្រៀនដោយប្រធានកូរ៉ុមឌីកុនអាយុ 13 ឆ្នាំរូបនេះ អំពីអំណាចនៃវិវរណៈដែលកើតមានចំពោះអ្នកដែលមានកូនសោដ៏ពិសិដ្ឋនៃគណៈប្រធាន ដោយមិនអាស្រ័យលើប្រាជ្ញា ភិនភាគ ឬអាយុរបស់គេឡើយ ។

ខ្ញុំបានឆ្លើយថា « ខ្ញុំមិនដឹងនោះទេ ។ តើប្អូនគិតយ៉ាងម៉េចដែរ ? » ហើយគាត់បាននិយាយថា « យើងត្រូវរកឲ្យឃើញពីវិធីដើម្បីជួយគាត់ឲ្យមកបានទៀងទាត់ ។ ខ្ញុំដឹងថាមានពីរនាក់ទៀតដែលគួរចូលរួមក្នុងកូរ៉ុមយើង តែគេមិនបានមក ហើយខ្ញុំមិនបានស្គាល់គេទេ ។ ប្រហែលខ្ញុំអាចធ្វើជាមិត្តនឹងពួកគេម្នាក់ ហើយឲ្យទីប្រឹក្សារបស់ខ្ញុំធ្វើជាមិត្តនឹងម្នាក់ទៀត ។ បើពួកគេទាំងអស់គ្នាមក នោះយើងនឹងមានប្រាំពីរនាក់ ចុះតើទៅរកប្រាំនាក់ទៀតមកពីណាបាន ? »

ខ្ញុំឆ្លើយថា « ខ្ញុំមិនដឹងនោះទេ – តែបើព្រះវរបិតាសួគ៌ចង់ឲ្យពួកគេនៅទីនោះ ទ្រង់ដឹង » ។

រួចគាត់បានសួរថា « អញ្ចឹងយើងត្រូវអធិស្ឋានក្នុងនាមជាគណៈប្រធាន និងកូរ៉ុមរកឲ្យឃើញនូវកិច្ចការដែលត្រូវធ្វើ ។ តើខ្ញុំគ្រប់គ្រងក្មេងប្រុសទាំងអស់ក្នុងវួដដែលមានអាយុឌីកុន ទោះពុំមែនជាសមាជិកក្ដីមែនទេ ? »

ដោយក្ដីស្ញើច ខ្ញុំបាននិយាយថា « ក្នុងព្រះនេត្រព្រះអម្ចាស់ តើប៊ីស្សពប្អូនមានទំនួលខុសត្រូវចំពោះតែសមាជិកក្នុងវួដ ឬចំពោះអ្នកដែលរស់នៅក្នុងដែនកំណត់វាមែនទេ ? »

« អ្នកតំណាងឲ្យព្រះអម្ចាស់ »វ័យក្មេងនេះបានយល់ ។ គាត់បានស្គាល់ពីតួនាទីរបស់ឌីកុន គ្រូ និងសង្ឃក្នុងការមើលខុសត្រូវលើសាសនាចក្រ និងអញ្ជើញមនុស្សទាំងអស់ឲ្យមករកព្រះគ្រីស្ទ ។

គំនិតខ្ញុំបានបែរទៅរកខគម្ពីរមួយ ពេលខ្ញុំគិតពីយុវជនយុវនារីដ៏ឆ្នើមក្នុងសាសនាចក្រ --- ជាខមួយដែលម៉ូរ៉ូណៃបាននិយាយទៅយ៉ូសែប ស៊្មីធ ដោយនិយាយថា វា « ពុំទាន់បានសម្រេចនៅឡើយទេ ប៉ុន្តែនឹងបានសម្រេចនៅពេលឆាប់ៗ » ( យ៉ូសែប ស៊្មីធ --- ប្រវត្តិ 1:41 ) ។

« ក្រោយគ្រានោះ យើងនឹងចាក់វិញ្ញាណរបស់យើងទៅលើគ្រប់ទាំងមនុស្ស នោះកូនប្រុសស្រីរបស់អ្នកនឹងទាយ ... ពួកកំលោះៗរបស់អ្នកនឹងឃើញការជាក់ស្ដែង » ( យ៉ូអែល 2:28 ) ។

អ្វីដែល « ផុសឡើង »ក្នុងគំនិតរបស់ប្រធានវ័យក្មេងនេះគឺជាការនិមិត្តមួយពីអ្វីដែលព្រះវរបិតាសួគ៌ចង់កូរ៉ុមរបស់គាត់ប្រែក្លាយ ។ វាគឺជាវិវរណៈដែលគាត់ត្រូវពង្រឹងដល់សមាជិកសកម្មក្នុងកូរ៉ុមរបស់គាត់ សង្គ្រោះអ្នកដែលជួបបញ្ហា ហើយអញ្ជើញមនុស្សទាំងអស់ឲ្យមករកព្រះគ្រីស្ទ ។ ដោយមានការបំផុសបែបនេះ គាត់រៀបផែនការអនុវត្តនូវឆន្ទៈនៃព្រះអម្ចាស់ ។
ព្រះអម្ចាស់បានបង្រៀនដល់ប្រធានវ័យក្មេងនេះថា « បព្វជិតភាព » គឺជាការជួយបម្រើដល់អ្នកដទៃ ។ ដូចដែលព្យាការីជាទីស្រឡាញ់របស់យើង ប្រធាន ថូម៉ាស អេស ម៉នសុន បានពន្យល់ថា ៖ « បព្វជិតភាពគឺពុំមែនជាអំណោយទាននោះទេ តែវាជាការអនុញ្ញាតឲ្យបម្រើ ជាឯកសិទ្ធិក្នុងការជួយ និងជាឱកាសដើម្បីប្រទានពរដល់ជីវិតរបស់អ្នកដទៃ » ( នៅក្នុង « Our Sacred Priesthood Trust » *Ensign* ខែ ឧសភា ឆ្នាំ 2006 ទំព័រ 57 ) ។

ការបម្រើគឺជាគ្រឹះដ៏សំខាន់នៃបព្វជិតភាព --- ជាការបម្រើដល់អ្នកដទៃ ដូចដែលបានបង្ហាញដោយព្រះអង្គសង្គ្រោះ ។ ខ្ញុំសូមថ្លែងទីបន្ទាល់ថា នេះគឺជាបព្វជិតភាពរបស់ទ្រង់ យើងកំពុងធ្វើកិច្ចការទ្រង់ ហើយទ្រង់បានបង្ហាញដល់រាល់អ្នកកាន់បព្វជិតភាពពីវិធីនៃការបម្រើដ៏ស្មោះត្រង់ក្នុងបព្វជិតភាព ។

ខ្ញុំសូមអញ្ជើញគណៈប្រធានកូរ៉ុមនីមួយៗឲ្យប្រឹក្សា សិក្សា ហើយអធិស្ឋានជាទៀងទាត់ដើម្បីរៀនពីឆន្ទៈព្រះអម្ចាស់ចំពោះកូរ៉ុមអ្នក រួចហើយចេញទៅធ្វើវា ។ សូមប្រើសៀវភៅកាតព្វកិច្ចចំពោះព្រះ ដើម្បីជួយអ្នកបង្រៀនដល់សមាជិកកូរ៉ុមអ្នកពីភារកិច្ចពួកគេ ។ ខ្ញុំអញ្ជើញសមាជិកកូរ៉ុមម្នាក់ៗឲ្យគាំទ្រដល់ប្រធានកូរ៉ុមរបស់អ្នក ហើយស្វែងរកពាក្យទូន្មានពីគាត់ ពេលអ្នករៀន និងបំពេញរាល់ភារកិច្ចបព្វជិតភាពរបស់អ្នកដោយសុចរិត ។ ហើយខ្ញុំសូមអញ្ជើញយើងគ្រប់គ្នាឲ្យមើលទៅយុវជនដ៏អស្ចារ្យទាំងនេះដូចដែលព្រះអម្ចាស់បានធ្វើ ---ថាពួកគេគឺជាធនធានដ៏សំខាន់ក្នុងការកសាង និងពង្រឹងដល់នគរទ្រង់នាពេលនេះ និងនៅទីនេះ ។

អ្នកដែលជាយុវជនដ៏ឆ្នើមមានកាន់បព្វជិតភាពអើរ៉ុន ដែលបានស្ដារឡើងវិញដល់យ៉ូសែប ស៊្មីធ និង អូលីវើរ ខៅឌើរី នៅក្បែរ ភូមិហារម៉ូនី រដ្ឋផែនស៊ីវ៉ាញ៉ា ដោយយ៉ូហាន បាទីស្ទ ។ បព្វជិតភាពរបស់អ្នកមានកូនសោដ៏ពិសិដ្ឋដើម្បីបើកទ្វារសម្រាប់កូនចៅព្រះវរបិតាសួគ៌ឲ្យមករកព្រះរាជបុត្រាទ្រង់ ព្រះយេស៊ូវគ្រីស្ទ និងដើរតាមទ្រង់ ។ នេះត្រូវបានផ្ដល់ឲ្យតាមរយៈ « ដំណឹងល្អពីការប្រែចិត្ត និងពីបុណ្យជ្រមុជទឹក និងពីការផ្ដាច់បាប » ពិធីបរិសុទ្ធនៃសាក្រាម៉ង់ប្រចាំសប្ដាហ៍ ហើយ « ការបម្រើពីពួកទេវតា » ។ អ្នកពិតជា « ពួកអ្នកបម្រើ » ដែលត្រូវមានភាពស្អាតស្អំ ភាពសក្ដិសម និងស្មោះត្រង់ ហើយជាបុរសដែលកាន់បព្វជិតភាពនៅគ្រប់ពេលវេលា និងគ្រប់ទីកន្លែង ។

ហេតុអ្វី? សូមស្ដាប់ប្រសាសន៍របស់គណៈប្រធានទីមួយរបស់យើង ដែលបានផ្ដល់សម្រាប់អ្នករាល់គ្នាថា ៖ « អ្នកមានសិទ្ធិអំណាចចាត់ចែងពិធីបរិសុទ្ធក្នុងបព្វជិតភាពអើរ៉ុន ... ។ អ្នកនឹងប្រទានពរយ៉ាងធំធេងដល់ជីវិតមនុស្សនៅជុំវិញអ្នក ... ។ ព្រះវរបិតាសួគ៌បានទុកព្រះទ័យ និងជឿជាក់យ៉ាងខ្លាំងចំពោះអ្នក ហើយមានបេសកកម្មមួយដ៏សំខាន់ដើម្បីអ្នកបំពេញ » ។ ( *Fulfilling My Duty to God* [ ឆ្នាំ 2010 ] ទំព័រ 5 ) ។

ខ្ញុំដឹងថាពាក្យទាំងនេះពិត ហើយខ្ញុំអធិស្ឋានថា យើងម្នាក់ៗនឹងទទួលនូវសាក្សីដូចគ្នានេះ ។ ហើយខ្ញុំនិយាយពាក្យទាំងនេះក្នុងព្រះនាមដ៏ពិសិដ្ឋនៃព្រះយេស៊ូវគ្រីស្ទ ដែលយើងកាន់នូវបព្វជិតភាពរបស់ទ្រង់ អាម៉ែន ។